# ផលផ្លែខាង

# ព្រះវិញ្ញាណ

ព្រះអម្ចាស់អើយ សូមចម្រើនកម្លាំងដល់ខ្ញុំ ដើម្បីឲ្យខ្ញុំទទួលបានព្រះចេស្តាទ្រង់ ដោយសារព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ តាមសិរីល្អនៃទ្រង់ដ៏ប្រសើរក្រៃលែង ឲ្យព្រះគ្រីស្ទបានសណ្ឋិតក្នុងចិត្តខ្ញុំ ដោយសារសេចក្ដីជំនឿ ប្រយោជន៍ឲ្យខ្ញុំបានចាក់ឫស ហើយតាំងមាំមួនក្នុងសេចក្ដីស្រឡាញ់ ។(១)

ខ្ញុំរស់នៅក្នុងព្រះវិញ្ញាណ នោះខ្ញុំនឹងមិនបំពេញសេចក្ដីប៉ងប្រាថ្នាខាងសាច់ឈាមទេ។ ព្រះវិញ្ញាណរបស់ទ្រង់បានដឹកនាំខ្ញុំ នោះខ្ញុំនឹងមិននៅក្រោមបន្ទុកក្រឹត្យវិន័យទៀតទេ ។(២)

តែឯផលផ្លែនៃព្រះវិញ្ញាណវិញ នោះគឺសេចក្ដីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ស្លូតបូត ហើយដឹងខ្នាត គ្មានក្រឹត្យវិន័យណាទាស់នឹងសេចក្ដីយ៉ាងនោះបានទេ ។(៣)

ពីព្រោះខ្ញុំជារបស់ផងព្រះគ្រីស្ទ នោះបានឆ្កាងសាច់ឈាមហើយ ព្រមទាំងសេចក្ដីរំជួល និងសេចក្ដីប៉ងប្រាថ្នាទាំងប៉ុន្មានផង។ (៤)

ដោយព្រោះថាខ្ញុំបានព្រោះខាងឯព្រះវិញ្ញាណ នោះខ្ញុំនឹងច្រូតបានជីវិតអស់កល្បជានិច្ច ពីព្រះវិញ្ញាណវិញ។ (៥)

**អាម៉ែន!**

(១) អេភេសូរ ៣: ១៦-១៧
(២) កាឡាទី ៥: ១៦-១៨
(៣) កាឡាទី ៥: ២២ , ២៣
(៤) កាឡាទី ៥: ២៤
(៥) កាឡាទី ៦: ៨

**អេភេសូរ ៣ : ១៦-១៧** ដើម្បីឲ្យទ្រង់បានប្រោសប្រទាន ឲ្យអ្នករាល់គ្នាបានព្រះចេស្តា ចំរើនកំឡាំងនៃមនុស្សខាងក្នុង ដោយសារព្រះវិញ្ញាណទ្រង់ តាមសិរីល្អនៃទ្រង់ដ៏ប្រសើរក្រៃលែង១៧ ឲ្យព្រះគ្រីស្ទបានសណ្ឋិតក្នុងចិត្តអ្នករាល់គ្នា ដោយសារសេចក្តីជំនឿ ប្រយោជន៍ឲ្យអ្នករាល់គ្នាបានចាក់ឫស ហើយតាំងមាំមួនក្នុងសេចក្តីស្រឡាញ់ ។

**កាឡាទី ៥: ១៦-១៨** តែខ្ញុំប្រាប់ថា ចូរដើរក្នុងព្រះវិញ្ញាណ នោះអ្នករាល់គ្នានឹងមិនបំពេញសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាមទេ ១៧ ដ្បិតសាច់ឈាមតែងតែប៉ងប្រាថ្នាទាស់នឹងព្រះវិញ្ញាណ ឯព្រះវិញ្ញាណ ទ្រង់ក៏ទាស់នឹងសាច់ឈាមដែរ សេចក្តីទាំង២នេះប្រឆាំងនឹងគ្នា ដល់ម៉្លេះបានជាអ្នករាល់គ្នារកធ្វើការ ដែលចង់ធ្វើទៅមិនកើត ១៨ បើព្រះវិញ្ញាណទ្រង់នាំអ្នករាល់គ្នាវិញ នោះអ្នករាល់គ្នាមិននៅក្រោមបន្ទុកក្រឹត្យវិន័យទៀតទេ ។

**កាឡាទី ៥: ២២-២៥** តែឯផលផ្លែនៃព្រះវិញ្ញាណវិញ នោះគឺសេចក្តីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ២៣ ស្លូតបូត ហើយដឹងខ្នាត គ្មានក្រឹត្យវិន័យណាទាស់នឹងសេចក្តីយ៉ាងនោះទេ ២៤ ហើយអស់អ្នកដែលជារបស់ផងព្រះគ្រីស្ទ នោះបានឆ្កាងសាច់ឈាមហើយ ព្រមទាំងសេចក្តីរំជួល និងសេចក្តីប៉ងប្រាថ្នាទាំងប៉ុន្មានផង ២៥ បើសិនជាយើងរស់ដោយនូវព្រះវិញ្ញាណ នោះត្រូវដើរដោយព្រះវិញ្ញាណដែរ។

**កាឡាទី ៦: ៨** អ្នកណាដែលព្រោះខាងឯសាច់ឈាមរបស់ខ្លួន នឹងច្រូតបានសេចក្តីពុករលួយពីសាច់ឈាមនោះឯង តែអ្នកណាដែលព្រោះខាងឯព្រះវិញ្ញាណ នោះនឹងច្រូតបានជីវិតអស់កល្បជានិច្ច ពីព្រះវិញ្ញាណវិញ។


**បកប្រែដោយ: ONE -2- ONE CAMBODIA**

**អាស័យដ្ឋាន: # ៣៨ - ៣៨A ផ្លូវលេខ ៣៣៦**

**សង្កាត់ទឹកល្អក់៣ ខ័ណ្ឌទួលគោក**

**រាជធានីភ្នំពេញ ប្រទេសកម្ពុជា**

www.One-2-One world.org

www.derekprince.co.nz PC12